ព័ត៌មានពីសាលាបឋមសិក្សា
ខែមិថុនា ឆ្នាំ២០១៩

វុល:២
បោះផ្សាយលើកទី១០

អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប
International School of Siem Reap




# ព័ត៌មានពីសាលាបឋមសិក្សាសម្រាប់ខែមិថុនា ឆ្នាំ២០១៩

## ឆ្នាំសិក្សា ២០១៨-២០១៩

សូមជម្រាបជូនលោក-លោកស្រីដែលជាអាណាព្យាបាលទាំងអស់ជាទីគោរព,
ឆ្នាំសិក្សា២០១៨-២០១៩បានឈានចូលមកដល់ថ្ងៃបិទវគ្គក្នុងពេលដ៏ខ្លីខាងមុខនេះ។ ការសិក្សាក្នុងអាគារថ្មីរយៈពេលជិតមួយឆ្នាំ ព្រមទាំងបានឆ្លងកាត់កម្មវិធីជាច្រើនដូចជា៖ សប្តាហ៍អន្តរជាតិ កម្មវិធីជួបជុំអាណាព្យាបាលសិស្ស កម្មវិធីបុណ្យណូអែល ។ល។
នាងខ្ញុំសូមស្ញើចសរសើរ សិស្សានុសិស្សទាំងអស់ ដែលខិតខំប្រឹងប្រែងចំពោះការសិក្សាបានយ៉ាងល្អ និងបានបង្ហាញអំពីការស្រលាញ់ការសិក្សាតាំងពីដើមឆ្នាំរហូតដល់ចុងឆ្នាំសិក្សាផងដែរ។ តាងនាងខ្ញុំ ជានាយកប្រតិបត្តិភាសាអង់គ្លេស សូមថ្លែងអំណរគុណដល់លោកគ្រូអ្នកគ្រូបង្រៀនទាំងអស់ ព្រមទាំងបុគ្គលិកគ្រប់ផ្នែកដែលបានចូលរួមជួយសហការក្នុងដំណើរការអប់រំនៃសាលាអន្តរជាតិ ISSRពេញមួយឆ្នាំដែលនាំឲ្យកិច្ចការអប់រំប្រកបទៅបានដោយជោគជ័យ។ ក្នុងឱកាសនៃការឈប់សម្រាកនាពេលខាងមុខ នាងខ្ញុំសូមប្រសិទ្ធិពរជ័យដល់លោក-លោកស្រី អាណាព្យាបាល ព្រមទាំងបុគ្គលិកគ្រប់ជាន់ថ្នាក់ឲ្យជួបតែសំណាងល្អគ្រប់ៗគ្នា។ នាងខ្ញុំ សង្ឃឹមថានឹងបានជួបលោក-លោកស្រី សិស្សានុសិស្សទាំងអស់នៅសាលាបឋមសិក្សា នៅថ្ងៃចន្ទ ទី១២ ខែសីហា ឆ្នាំ២០១៩ ឆ្នាំសិក្សាថ្មីខាងមុខ។

## អំពីការសិក្សាលើ ទំនៀមទម្លាប់ជាតិសាសន៍ដទៃ





លោកគ្រូអ្នកគ្រូ បានរៀបចំឲ្យមានសកម្មភាពសិក្សាពីប្រទេសខុសៗគ្នា និងបង្ហាញពីវប្បធម៌ផ្សេងៗគ្នាកំឡុងពេល International Week។ ថ្នាក់នីមួយៗត្រូវផ្តោតចម្បងទៅលើតែប្រទេសតែមួយគត់ដើម្បីរៀបចំតុបតែងក្នុងថ្នាក់។ក្នុងនោះរួមមានប្រទេសក្រិច ប្រទេសណេប៉ាល់ ប្រទេសប្រេស៊ីល ប្រទេស Ghana។ សិស្សបានសិក្សាអំពីប្រទេសទាំងនេះ និងរៀនអំពីវប្បធម៌ក្នុងពេលតែមួយ ខណៈពេលដែលទៅដើរទស្សនាតាមថ្នាក់ផ្សេងៗ។

ថ្នាក់រៀនមួយចំនួន មានមាតាបិតា អាណាព្យាបាលសិស្សចូលរួមក្នុងការចែករំលែកបទពិសោធន៍ដល់កូនៗក្នុងថ្នាក់។ ចំណែកសិស្សានុសិស្សក៏មានឱកាសក្នុងការបន្តរទៅចូលរួមក្នុងថ្នាក់ដទៃទៀតជាបន្តបន្ទាប់ ដើម្បីសិក្សាពីប្រទេសខុសៗគ្នា។ នាងខ្ញុំសូមថ្លែងអំណរគុណដល់ការចូលរួមសហការល្អ ពីសិស្សានុសិស្ស បុគ្គលិក លោក-លោកស្រី ដែលបានជំរុញកម្មវិធី International Week ប្រព្រឹត្តទៅពេញមួយសប្តាហ៍ និងពរពេញទៅដោយអនុស្សាវរីយ៍ជាច្រើន។ សូមថ្លែងអំណដល់លោកគ្រូ Glen ក្នុងការដឹកនាំ ដំណើរការមេរៀន សិក្សាលើទំនៀមទម្លាប់ នៃជាតិសាសន៍ ផ្សេងទៀតពេញមួយសប្តាហ៍។










## កម្មវិធីសប្បុរសធម៌ ដល់មន្ទីរពេទ្យកុមារអង្គរ និងមន្ទីរពេទ្យគន្ធបុប្ផា

កម្មវិធីសប្បុរសធម៌ របស់សាលាអន្តរជាតិ ISSR បានប្រមូលថវិកាសរុបចំនួន ៣០១០ ដុល្លារអាមេរិច នឹងបានប្រគល់ជូនមន្ទីរពេទ្យកុមារអង្គរ មន្ទីរពេទ្យគន្ធបុប្ផាផងដែរ។ សាលាបានធ្វើការប្រមូលថវិកាតាមរយៈកម្មវិធី ដូចជា៖ កម្មវិធី School Fair, បុណ្យ Halloween និងកីឡាហែលទឹកប្រចាំឆ្នាំ។ នាងខ្ញុំពិតជាមានចិត្តសប្បាយរីករាយក្រៃលែងដល់លោក-លោកស្រីដែលបានចូលរួមជួយក្នុងដំណើរការសប្បុរសធម៌នេះ។ សូមអរគុណដល់ក្រុមសិស្ស តំណាងសាលាដែលបានចូលរួមប្រគល់ថវិកាជូនដល់មន្ទីរពេទ្យកុមារទាំងនោះ។



## បញ្ជីរាយនាមលោកគ្រូអ្នកគ្រូនិងថ្នាក់សិក្សាឆ្នាំសិក្សាថ្មី២០១៩-២០

ក្នុងឆ្នាំសិក្សានីមួយៗតែងមានការចាកចេញពីសំណាក់លោកគ្រូអ្នកគ្រូក្រោយបញ្ចប់ការបង្រៀនរបស់ពួកគាត់ តែលោកគ្រូអ្នកគ្រូទាំងអស់បានបង្ហាញអំពីកិច្ចការងាររបស់ខ្លួនពរពេញដោយទំនួលខុសត្រូវ ពិសេសបានបង្រៀនសិស្សានុសិស្សទាំងអស់រហូតដល់បំណាច់ឆ្នាំសិក្សា។ នាងខ្ញុំសូមគោរពជូនពរដល់លោកគ្រូអ្នកគ្រូឲ្យជួបតែសុខសុវត្ថិភាព ហើយរក្សាទំនាក់ទំនងល្អជាមួយសាលាបន្តទៅទៀត។
តារាងខាងក្រោមគឺជាព័ត៌មានសង្ខេបរបស់លោកគ្រូអ្នកគ្រូ ក្នុងឆ្នាំសិក្សាថ្មី២០១៩-២០២០។ នាងខ្ញុំសូមស្វាគមន៍ លោកគ្រូអ្នកគ្រូចូលរួមបង្រៀនជាមួយនឹងសាលាអន្តរជាតិ ISSR នៅឆ្នាំសិក្សាថ្មី ។ ខ្ញុំជឿជាក់ថាលោកគ្រូ អ្នកគ្រូក៏រីករាយក្នុងការសហការល្អជាមួយសាលារបស់យើង និង ផ្តល់គុណភាពអប់រំដល់សិក្សានុសិស្សទាំងអស់គ្នាបានយ៉ាងល្អប្រសើរផងដែរ។

| ថ្នាក់ក្នុងឆ្នាំសិក្សា២០១៨-១៩ | ថ្នាក់ក្នុងឆ្នាំសិក្សា២០១៩-២០ | ឈ្មោះគ្រូបន្ទុកថ្នាក់ |
|---|---|---|
| ថ្នាក់ Nursery | ថ្នាក់ Reception 1A | អ្នកគ្រូ Erin |
| | ថ្នាក់ Reception 1B | លោកគ្រូ Sean |
| ថ្នាក់ Reception 1A | ថ្នាក់ Reception 2A | អ្នកគ្រូ Amy |
| ថ្នាក់ Reception 1B | ថ្នាក់ Reception 2B | អ្នកគ្រូ Kristina |
| ថ្នាក់ Reception 2A | ថ្នាក់ 1A | អ្នកគ្រូ Nicola |
| ថ្នាក់ Reception 2B | ថ្នាក់ 1B | TBC |
| ថ្នាក់ទី 1A | ថ្នាក់ 2A | អ្នកគ្រូ Hayley |
| ថ្នាក់ទី 1B | ថ្នាក់ 2B | លោកគ្រូ Philip |
| ថ្នាក់ទី 2A | ថ្នាក់ 3A | TBC |
| ថ្នាក់ទី 2B | ថ្នាក់ 3B | អ្នកគ្រូ Gemma |
| ថ្នាក់ទី 3A | ថ្នាក់ 4A | អ្នកគ្រូ Bernadette |
| ថ្នាក់ទី 3B | ថ្នាក់ 4B | អ្នកគ្រូ Rene |
| ថ្នាក់ទី 4A | ថ្នាក់ 5A | លោកគ្រូ Glen |
| ថ្នាក់ទី 5A | ថ្នាក់ទី 6A | អ្នកគ្រូ Beckie |
| ថ្នាក់ទី 5B | | |

ISSR

ថ្ងៃប្រារព្ធពិធី បិទបវេសនកាល
និងប្រព្រឹត្តទៅ
នៅថ្ងៃសុក្រ ទី២១ ខែមិថុនា ឆ្នាំ២០១៩
វេលាម៉ោង៩:00 ព្រឹក។ សូមលោក-លោកស្រីអញ្ជើញចូលរួមឲ្យបានគ្រប់ៗគ្នា។

ថ្ងៃឈប់សម្រាកឆ្នាំសិក្សា២០១៨-១៩ ចាប់ផ្តើមពីថ្ងៃសុក្រ ទី២១ ខែមិថុនា ឆ្នាំ ២០១៩ បន្ទាប់ពីកម្មវិធីប្រគុំតន្ត្រីបិទវគ្គបញ្ចប់។ ដូចនេះ សូមលោក-លោកស្រីអញ្ជើញមកទទួលកូនៗនៅឯកន្លែងញ៉ាំអាហារនៅជាន់ក្រោម។

សូមថ្លែងអំណរគុណអ្នកគ្រូ Chantal ក្នុងការបង្វឹកសិស្សានុសិស្ស ផ្នែកដូរតន្ត្រីប្រកបដោយគុណភាព។ សិស្សទាំងអស់សម្តែងបានបានយ៉ាងជំនាញ។






*We are one,*

*But we are many.*